## ស្ថានភាពអតិផរណានៅខែកុម្ភៈ ឆ្នាំ២០១៧

### ក/ អតិផរណាក្នុងប្រទេស

ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបានកើនឡើងក្នុងអត្រាទាបត្រឹម 0,១% ធៀបនឹងខែមុន និងបានកើនឡើង ៤,0% បើធៀបនឹង១២ខែមុន។ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញប្រើប្រាស់មួយចំនួនបានថយចុះ ដូចជាសន្ទស្សន៍ថ្លៃម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ដោយសារមានការថយចុះថ្លៃសាច់ជ្រូក សាច់មាន់ សាច់ទានិងថ្លៃបន្លែ, សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត, សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់និងការថែទាំក្នុងផ្ទះ, និងសន្ទស្សន៍ថ្លៃការកំសាន្តនិងវប្បធម៌ជាដើម។ ប៉ុន្តែសន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ដោយសារកំណើនថ្លៃប្រេងសាំង(កើន១,៨%)និងប្រេងម៉ាស៊ូត(កើន១,៧%), និងសន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ក៏បានកើនឡើងផងដែរ ដែលក្នុងនោះថ្លៃស្រាកើន0,៤% និងថ្លៃថ្នាំជក់កើន0,៣%។

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួននៅបន្តកើនឡើង ដូចជាសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង (កើន៥,៦%) ដោយសារកំណើនថ្លៃសាច់គោ សាច់មាន់ សាច់ជ្រូកនិងត្រីស្រស់, សន្ទស្សន៍ថ្លៃការដឹកជញ្ជូន (កើន៣,៧%) ដោយសារកំណើនថ្លៃប្រេងសាំងនិងប្រេងម៉ាស៊ូតស្របនឹងនិន្នាការកំណើនថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិគិតចាប់ពីចុងឆ្នាំ២០១៦មក ដោយសារការកាត់បន្ថយទិន្នផលផលិតកម្មប្រេងរបស់ប្រទេសសមាជិកOPEC។

| តារាង១÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម | | |
|---|---|---|
| | ធៀបខែមុន | ធៀប១២ខែមុន |
| **មុខទំនិញគ្រប់មុខ** | **+0,១** | **+៤,0** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | 0,0 | +៥,៦ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +0,៣ | +៣,៥ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +0,១ | +៣,៨ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈ | -0,២ | +0,១ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការ | -0,១ | +២,២ |
| ៦-សុខាភិបាល | 0,0 | +២,0 |
| ៧-ការដឹកជញ្ជូន | +0,៦ | +៣,៧ |
| ៨-គមនាគមន៍ | 0,0 | -0,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | -0,១ | +២,៤ |
| ១0-ការសិក្សា | 0,0 | 0,0 |
| ១១-ភោជនីយដ្ឋាន | +0,២ | +៣,៥ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -0,១ | +២,៩ |

| តារាង២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៦ | ២០១៧ | | ២០១៦ | ២០១៧ | |
| | ធ្នូ | មករា | កុម្ភៈ | ធ្នូ | មករា | កុម្ភៈ |
| អង្ករ | +០,៥ | -០,៥ | +០,៣ | +៣,៦ | +២,៦ | +២,៩ |
| សាច់គោ | +០,៣ | +០,៣ | ០,០ | +៦,៦ | +៦,១ | +៤,៤ |
| សាច់មាន់ | +០,៣ | +០,៩ | -០,៤ | +៧,៦ | +៨,៤ | +៦,០ |
| សាច់ទា | +០,៧ | +០,១ | -០,៧ | +១,០ | +១,៧ | +០,៧ |
| សាច់ជ្រូក | +០,៦ | +០,៥ | -០,២ | +៣,៥ | +៤,៦ | +៣,២ |
| ត្រីទឹកសាបនិងត្រីទឹកសមុទ្រ | +០,៤ | ០,០ | +០,៥ | +៩,៥ | +៩,៦ | +១០,០ |
| ក្នុងនោះត្រីស្រស់ | +០,៣ | +០,២ | +០,៥ | +៩,៦ | +១០,១ | +១០,៧ |
| ផ្លែឈើ | +០,៦ | +០,៦ | -០,១ | +៥,១ | +៦,២ | +៣,៩ |
| ផ្លែឈើស្រស់ | +០,៨ | +០,៦ | ០,០ | +៥,១ | +៦,៤ | +៤,២ |
| បន្លែ | +០,១ | +០,៣ | -០,៦ | +១៣,៦ | +១៥,៧ | +១៣,២ |
| បន្លែជាស្លឹក | +០,៦ | -០,២ | -០,៨ | +១៣,០ | +១៦,៦ | +១៤,៣ |
| បន្លែជាផ្លែ | -០,៦ | +១,២ | -១,៦ | +២៣,២ | +២៦,១ | +២០,៧ |

## ៦/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង៣÷ អតិផរណាប្រចាំឆ្នាំ (%) | | | | |
|---|---|---|---|---|
| ប្រទេស | ២០១៦ | | ២០១៧ | |
| | មករា | កុម្ភៈ | មករា | កុម្ភៈ |
| ប្រទេសកម្ពុជា | 3.0 | 2.3 | 4.4 | 4.0 |
| ប្រទេសវៀតណាម | 0.8 | 1.3 | 5.2 | 5.0 |
| ប្រទេសថៃ | -0.5 | -0.5 | 1.6 | 1.4 |
| ប្រទេសម៉ាឡេស៊ី | 3.5 | 4.2 | 3.2 | 4.5 |
| ប្រទេសឥណ្ឌូនេស៊ី | 4.1 | 4.4 | 3.5 | 3.8 |
| ប្រទេសហ្វីលីពីន | 1.4 | 0.9 | 2.7 | 3.3 |
| ប្រទេសចិន | 1.8 | 2.3 | 2.5 | 0.8 |
| ប្រទេសកូរ៉េខាងត្បូង | 0.8 | 1.2 | 2.0 | 1.9 |
| ប្រទេសជប៉ុន | -0.1 | 0.3 | 0.4 | 0.3 |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត ពីគេហទំព័រ http://www.tradingeconomics.com

<u>**កំណត់សម្គាល់**</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

*រៀបចំនិងធ្វើចំណោលដោយ*

*នាយដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*